
ញ៉ុក . ថែម
មហាវេស្សន្តរជាតក
កណ្ឌទី ១២
រក្សាសិទ្ធិគ្រប់យ៉ាង
គ.ស ២០០៦

# មហាវេស្សន្តរជាតក

## ទី ១២

## កណ្ឌកុមារ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ជាលិកុមារោបិ មុចលិន្ទសរតីរេ ខណ្ឌាវារំ និវាសាបេត្វា ចតុទ្ទស រថសហស្សានិ អាគតមគ្គាភិមុខានេវ ឋបាបេត្វា តស្មឹ តស្មឹ បទេសេ សីហព្យគ្ឃទីបិខគ្គាទីសុ អារក្ខំ សំវិទហិ ។

តោ សាធវោ ហែសាធុសប្បុរសផងទាំងឡាយអើយ កាលនោះព្រះជាលីកុមារ ជាមគ្គុទ្ទេសក៍វិសេស នាំផ្លូវព្រះមហាក្សត្រទាំងពីរព្រះអង្គ ទៅដល់មុចលិន្ទស្រះហើយ ព្រះជាលីកុមារក៏រណ្ដាប់តាក់តែងឱ្យដាក់ទ័ពទាយរាយចំណាត ចតចាំព្រះមហាក្សត្រជាស្រេចរឹងរទេះទាំងមួយម៉ឺនបួនពាន់ ក៏ឱ្យបង្វិលចំពោះមុខទៅកាន់ផ្លូវដំណើរដែលមក ប្រយោជន៍ដើម្បីនឹងឱ្យនៅចាំពិភក្តិរក្សាអស់ពលផង កុំបីឱ្យសត្វទាំងឡាយ មានរាជសីហ៍ ខ្លាធំ ខ្លាដំបង រមាស ជាដើមចូលមក

Websites: WatKhemaraRatanaram.org or WatKhmers.org

បៀតបៀនបានឡើយ ហត្ថិអាជីនំ សង្ឃោ មហា អហោសិ បពិត្រ អើយ រីសព្ទដំរីសេះរទេះ មួយអន្លើនូវអស់ពលផងទាំងឡាយ សឹងឮសន្ធឹកនោះមហិមាក្រៃពេក ។

អថ មហាសត្តោ តំ សទ្ទំ សុត្វា កាលនោះព្រះមហាសត្វទ្រង់ជ្រាបហើយ ទ្រង់ព្រះចិន្តាពិចារណាថា ឱសត្រូវផងទាំងឡាយអើយ សមវាទៅចោមរោមចាប់ស្លាប់ឯសម្តេចព្រះវរបិតាអញហើយ សមវាមកចោមរោមចាប់សម្លាប់ឯអញនេះផង ។ ព្រះអង្គទ្រង់ព្រះតម្រិះថា ឱអញអើយ សមនឹងក្ស័យប្រល័យជីវិត ដោយពួកសត្រូវនេះឯងមិនទេឡើយ ។ ព្រះអង្គទ្រង់ព្រះចិន្តាពិចារណាហើយ នូវប្រការអម្បាលណោះហើយ ព្រះអង្គភិតភ័យខ្លាច ពុំអាចដើម្បីទប់ទល់តម្កល់អាត្មាភាពនោះបានឡើយ ។ លុះដល់ចាប់ព្រះហស្តព្រះនាងមទ្រី នាំឡើងទៅលើកំពូលភ្នំវង្កតក្ខរ ទ្រង់ទតរមិលមើលទៅអស់សេនាយោធាផងទាំងឡាយនោះហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះអង្គបានត្រាស់

ហើយ ព្រះអង្គបន្ទូលនឹងអស់ភិក្ខុផងទាំងឡាយ ទ្រង់សូត្រសាជាបាទព្រះគាថាដូច្នេះ ៖

តេសំ សុត្វាន និគ្ឃោសំ ភីតោ វេស្សន្តរោ អហុ
បព្វតំ អភិរូហិត្វា ភីតោ សេនំ ឧទិក្ខតិ ។
ឥង្ឃ មទ្ទិ និសាមេហិ និគ្ឃោសោ យាទិសោ វនេ
អាជានិយា ហសិស្សន្តិ ធជគ្គានេវ ទិស្សរេ ។
ឥមេ នូន អរញ្ញម្ហិ មិគសង្ឃានិ លុទ្ទកា
វាគុរាហិ បរិក្ខិប្ប សោព្ភេ ចាតេត្វា តាវនេ
វិក្កោសមានា តិព្វាហិ ហន្តិ នេសំ វរំ វរំ ។
តថា មយំ អទូសកា អរញ្ញេ អវរុទ្ធកា
អមិត្តហត្ថត្តគតា បស្ស ទុព្វលឃាតកន្តិ ។

ភិក្ខុអើយ រីព្រះបាទស្រីវេស្សន្តរ ឮស័ព្ទពលសកលយោធានៃព្រះបាទស្រីសញ្ជ័យ ដ៏ជាសម្ដេចព្រះវរបិតានោះហើយ មានព្រះរាជហឫទ័យភិតភ័យខ្លាច មិនអាចដើម្បីនឹងទប់ទល់តម្កល់អាត្មាភាពបានឡើយ ទ្រង់ចាប់ព្រះហស្តព្រះនាងមទ្រី ឡើងទៅលើកំពូលភ្នំនោះ

Websites: WatKhemaraRatanaram.org or WatKhmers.org

ហើយ មានព្រះបន្ទូលថា មទ្រីនាងអើយ ចូរនាងពិតពិលរមិលមើលទៅ អស់សេនាសត្រូវផងទាំងឡាយ នាងអើយ នាងស្ដាប់ឯសព្ទដំរីស័ព្ទសេះ ស័ព្ទរទេះ នាងអើយ ចូរនាងរមិលមើលឯចុងទង់ជ័យនោះយល់ប្រកិតមកថា ឱដូចអញគិតនេះហើយ នាយើងទាំងពីរនេះឧបមាបីដូចសត្វម្រឹគ ត្រូវព្រានព្រៃវាមកចោមរោមស្ទាក់ព័ទ្ធជុំវិញហើយធ្វើអន្ទាក់ចាក់ជង់សង់ចម្រូង ជីកអណ្ដូងរំលុងហើយ វាចូលមកបង្អើលឱ្យរត់ទៅត្រូវរំលុងត្រូវចម្រូងអណ្ដូងវានោះ វាយកលំពែងស្នែងក្របីមកចាក់ឱ្យក្ស័យប្រល័យជីវិតស្រេចហើយ វាយកទៅធ្វើជាចំណីអាហារវារហាក់នោះ តើមានប្រការដូចម្ដេចមិញ នាយើងទាំងពីរនេះនឹងលុះក្នុងកណ្ដាប់ដៃសត្រូវនោះ មានឧបមេយ្យដូច្នោះហោង ។ រីព្រះពោធិសត្វ ហេតុតែភ័យខ្លាចស្លាប់នោះមិញ លុះដល់ទ្រង់ព្រះកន្សែងថ្លែងពិលាប ដោយនូវប្រការអម្បាលណោះហោង ។

ក្សិណនោះ ព្រះនាងមទ្រីទតរមិលមើលទៅ អស់សេនាយោធាផងទាំងឡាយ ព្រះនាងស្គាល់ជាក់ជាពលសកលយោធា-សេនាមាត្យអាត្មាឯងដូច្នេះហើយ ព្រះនាងទូលលោមព្រះបរមពោធិ

Websites: WatKhemaraRatanaram.org or WatKhmers.org

សត្ថា ៖

អមិត្តា នប្បសហេយ្យុំ អគ្គិវ ឧទកណ្ណវេ
តនេវ ត្វំ វិចិន្តេហិ អបិ សោត្ថិ ឥតោ សិយាតិ ។

បពិត្រព្រះសម្មតិទេព មហារាជក្សត្រថ្លៃប្រសើរអើយ ព្រះអង្គភ័យខ្លាចអ្វីនឹងសត្រូវនោះ មានឧបមាបីដូចអ្នកយកភ្លើងគប់ទាំងពាន់ទៅរោលទឹកសមុទ្រថ្លាស បើនឹងក្តៅដល់តិចនោះ ឥតអង្គឹមានឡើយ ។ បពិត្រព្រះមហារាជអើយ ព្រះអង្គភ្លេចហើយហ៎ះ នាសម្តេចព្រះឥន្ទ្រាធិរាជប្រទានព្រះពរព្រះអង្គមិញតើ ថាទោះយោបីសត្រូវមកពីទឹកក្តី ពីគោកក្តី ពីស្ពាំក្តី ពីឆ្វេងក្តី នឹងមកចោមរោមព្រះអង្គប៉ុន្មាន ៗ ក្តីនោះ ក៏នឹងមកបៀតបៀនព្រះអង្គពុំបានឡើយ សឹងដ៏មកថ្វាយបង្គំប្រណម្យ សុំពរអំពីព្រះអង្គឯងវិញអេះ ។

ឯព្រះពោធិសត្វកាលណាបើបានឮព្រះនាងមទ្រី ទូលមិនឱ្យភិតភ័យខ្លាចសត្រូវនោះឡើយ ព្រះអង្គបន្ទោបង់នូវទុក្ខសោកស្រេចហើយ ស្តេចលីលាចុះមកពីលើភ្នំ មួយអន្លើនឹងព្រះនាងមទ្រី ទៅគង់នៅនាទ្វារព្រះបរមសាលារបស់ព្រះអង្គវិញហោង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសាន្ធូវបាទព្រះគាថាដូច្នេះ ៖

តតោ វេស្សន្តរោ រាជា ឱរោហិត្វាន បព្វតា

និសីទិ បណ្ណសាលាយំ ឧជុំ កត្វាន មានសន្តិ ។

ភិក្ខុអើយ កាលនោះព្រះបាទស្រីវេស្សន្តរ ស្ដេចចុះមកពីលើភ្នំមួយអន្លើនឹងព្រះនាងមទ្រី មកគង់នៅនាព្រះបរមសាលា ព្រះអង្គតម្រង់នូវព្រះស្មារតីនោះខ្ជាប់ហើយ មិនភិតភ័យខ្លាចសត្រូវនោះឡើយ ។

ក្សិណនោះ ព្រះបាទស្រីសញ្ជ័យមានព្រះបន្ទូលនឹងព្រះនាងផុស្សតីទេវីថា នាងអើយ បើយើងទាំងពីរចូលទៅព្រមគ្នាតែម្ដងហើយ សមបាវេស្សន្តរនឹងកើតទុក្ខសោកនោះច្រើនមហិមាក្រៃពេកហេតុនេះហោង នាងឱ្យអញទៅជាមុន ឱ្យបាវេស្សន្តរបន្ទោបង់នូវទុក្ខសោកហើយ សន្សឹមនាងទៅឯក្រោយអញ កាលបើនាងទៅបានបន្តិចហើយ សន្សឹមឱ្យថៅជាលីនិងមេក្រស្នាលីលាទៅជាអណ្ដាប់អណ្ដោយ

ក្រោយនាងហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គសម្តែងនូវបាទព្រះគាថាដូច្នេះ ៖

និវត្តយិត្វាន រថំ | វុដ្ឋាបេត្វាន សេនិយោ
ឯកំ អរញ្ញេ វិហរន្តំ | បិតា បុត្តំ ឧបាគមិ ។
ហត្ថិក្ខន្ធតោ ឱរុយ្ហ | ឯកំសោ បញ្ជលីកតោ
បរិកិណ្ណោ អមច្ចេហិ | បុត្តំ សិញ្ចិតុមាគមិ ។
តត្ថទ្ទស កុមារំ សោ | រម្មរូបំ សមាហិតំ
និសិន្នំ បណ្ណសាលាយំ | ឈាយន្តំ អកុតោភយន្តិ ។

ភិក្ខុអើយ កាលនោះ ព្រះមហាក្សត្រឱ្យប្រែបង្វិលព្រះរាជរថទៅក្រោយ ហើយស្តេចលីលាទៅកាន់សំណាក់ព្រះរាជបុត្រ មួយអន្លើនឹងអស់អាមាត្យផងទាំងឡាយ កាលណាបើស្តេចលីលាចូលទៅដល់ហើយ ស្តេចចុះពីលើកដំរីរ័ត្នមង្គលហើយ ស្តេចយកនូវព្រះពស្ត្របរិសុទ្ធស្ពាយឆៀងលើព្រះអង្សា លីលាចូលទៅ ដើម្បីនឹងអភិសេក

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះរាជបុត្រនោះហោង ។ ព្រះអង្គទ្រង់ទតឃើញព្រះរាជឱរស ទ្រង់ភេទបព្វជិត គង់ចូលឈានយ៉ាងខ្ជាប់ខ្ជួនក្នុងព្រះបណ្ណសាលា ឥតមានភិតភ័យអ្វីឡើយ ។

តញ្ច ទិស្វាន អាយន្តំ បិតរំ បុត្តគិទ្ធិនំ
វេស្សន្តរោ ច មទ្ទី ច បច្ចុគ្គន្ត្វា អវន្ទិសុំ ។
មទ្ទី ច សិរសា បាទេ សសុរស្សាភិវាទយិ
មទ្ទី អហញ្ហិ តេ ទេវ បាទេ វន្ទាមិ តេ ហុសា
តេសុ តត្ថ បលិសជ្ជ បាណិនា បរិមជ្ជថាតិ ។

កាលនោះ ព្រះបាទស្រីវេស្សន្តរ ព្រះអង្គគង់នៅនាព្រះបរមសាលា មួយអន្លើនឹងព្រះនាងមទ្រី ព្រះអង្គទតទៅយល់សម្តេចព្រះវរបិតាមកអំពីចម្ងាយហើយ ក៏ស្ទុះរត់ទៅទទួលសម្តេចព្រះវរបិតា ព្រះអង្គថ្វាយបង្គំស្រេចហើយ ទើបព្រះនាងមទ្រីថ្វាយបង្គំប្រណម្យទូលថា បពិត្រព្រះសម្មតិទេព មហារាជក្សត្រថ្លៃប្រសើរអើយ ខ្ញុំអម្ចាស់ឯងឈ្មោះនាងមទ្រីជាកូនប្រសាព្រះអង្គ ខ្ញុំអម្ចាស់មកក្រាបថ្វាយបង្គំក្រោមព្រះបាទព្រះអង្គ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ក្សិណនោះ ព្រះបាទស្រីសញ្ជ័យ យកព្រះហស្តដ៏ទន់ល្វន់ បីដូចក្រពុំឈូករ័ត្ន មកសណ្ឋិតលើព្រះបិដ្ឋិ បបោសអង្អែលព្រះនាងមទ្រីដ៏ជាកូនប្រសាហើយ ទ្រង់ព្រះកន្សែងពិលាបអាណិតអនាថ មុខគួរឱ្យអាសូរករុណាពេកហោង ។ លុះព្រះអង្គបន្ទោបង់នូវទុក្ខសោកស្រេចហើយ ស្តេចក៏គង់នៅជាសុខសប្បាយ ធ្វើប្រស្រ័យសាកសួរទទួលមួយអន្លើនឹងព្រះរាជបុត្រ សូត្រជាបាទព្រះគាថាដូច្នេះ

កច្ចិ វោ កុសលំ បុត្ត     កច្ចិ បុត្ត អនាមយំ
កច្ចិ ឧញ្ឆេន យាបេថ     កច្ចិ មូលផលា ពហូ ។
កច្ចិ ឌំសា មកសា ច     អប្បមេវ សីរីសបា
វនេ វាឡមិគាកិណ្ណេ     កច្ចិ ហិំសា ន វិជ្ជតីតិ ។

បុត្ត ម្នាលកូនសម្លាញ់អើយ ពីដូចអ្នកមកនៅនាឋានអាយនេះ តើសុខសប្បាយជាទេឬ ? ឬមួយក្រែងមានជម្ងឺអាពាធព្យាធិរោគាជរាមកបៀតបៀនអ្នកទាំងពីរ រីទុក្ខសោករោគភ័យចង្រៃ ឧបទ្រពផងទាំងឡាយ តើញុាំងមានឬទេ ។ ប្រការមួយសោត នឹងស្វែងរកផ្លែឈើមើមឈើផងទាំងឡាយមកចិញ្ចឹមជិវិត តើញុាំងមានឬទេ រីមូស

សុច ស្រាំងស្រួយ ខ្ចួយក្អែប មមង់មមាច កន្ទេចអាល នូវពស់តូច ពស់ធំ ច្រទ្បំនូវម្រឹគពាទ្បសាហាវយង់ឃ្នង តើញាំងប៉ងមកបៀតបៀនអ្នកទាំងពីរឬទេ ។ កាលនោះ ព្រះពោធិសត្វ ស្តាប់ព្រះបន្ទូលសម្តេចព្រះវរបិតាហើយ ក្រាបបង្គំទូលថា ៖

អត្ថិ នោ ជីវិកា ទេវ　　សា ច យាទិសិ កីទិសា

កសិរា ជីវិកា ហោម　　ឧញ្ឆាចរិយាយ ជីវិតំ ។

អនិទ្ធិនំ មហារាជ　　ទមេត្យស្សំវ សារថិ

ត្យម្ហា អនិទ្ធិកា ទន្តា　　អសមិទ្ធិ ទមេតិ នោ ។

អបិ នោ កិសានិ មំសានិ　　បិតុ មាតុ អទស្សនា

អវរុទ្ធានំ មហារាជ　　អរញ្ញេ ជីវិសោកិនន្តិ ។

ទេវ បពិត្រសម្តេចព្រះវររាជបិតាក្សត្រថ្លៃប្រសើរអើយ រីយើងទាំងពីរមកនៅព្រៃអាយ ដើម្បីនឹងស្វែងរកផ្លែឈើមើមឈើផងទាំងទ្បាយចិញ្ចឹមជីវិត ។ បពិត្រព្រះមហារាជអើយ រីនាងមទ្រីជាបុត្រប្រសារបស់ព្រះអង្គ តែនឹងស្វែងរកផ្លែឈើពុំដែលដាច់ទ្បើយ បីដូចនាយសារថី ទូន្មានសេះអាជានេយ្យ ឱ្យបានរបបបែបបទប្រពៃនោះ

Websites: WatKhemaraRatanaram.org or WatKhmers.org

មានប្រការដូចម្តេចមិញ រីនាងមទ្រីតែងនឹងស្វែងរកនោះ ពុំដែលខ្ជិល ឡើយ មានប្រការដូច្នោះដែរ ។ បពិត្រព្រះមហារាជអើយ រីយើង ទាំងពីរនេះ អ្នកស្រីពិរាស្ត្រគេបំបរបង់មកនៅនាព្រៃ ស្វែងរកចិញ្ចឹម ជីវិតរស់នៅច្រទ្បំនឹងទុក្ខសោកច្រើនក្រៃ។ បពិត្រមហារាជអើយ ហេតុ តែនាងមានសេចក្តីព្រួយលំបាកមហិមា ឯណានាងក៏ព្រាត់ប្រាសកូន ជាទុក្ខសោក ដ៏មានខ្លួនស្គាំងស្គមថមថយកំលាំង លឿងទាំងសម្បុរពុំ យល់ដូចប្រក្រតីឡើយ ។ រីព្រះពោធិសត្វ ព្រះអង្គសម្តែងប្រាប់ព្រះវរ រាជបិតា ដោយនូវសភាពជាអ្នកកំសត់ទុគ៌ត នូវប្រការអម្បាលណោះ ហើយ ព្រះអង្គបន្ទូលសួរអំពីពត៌មានអំពីព្រះរាជបុត្រ ទ្រង់សូត្រជា បាទព្រះគាថាដូច្នេះ ៖

យេបិ តេ សិវិសេដ្ឋស្ស ជាយាឧប្បត្តមាឧសា
ជាលី កណ្ហាជិនា ចុភោ ព្រាហ្មណស្ស វសានុគា
អច្ចាយិកស្ស លុទ្ទស្ស យោ នេ គាវោវ សុម្ភតិ ។
តេ រាជបុត្តិយា បុត្តេ យទិ ជានាថ សំសថ
បរិយាបុណាថ នោ ខិប្បំ សប្បទដ្ឋំវ មាណវន្តិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

បពិត្រសម្តេចព្រះវរបិតាក្សត្រថ្លៃប្រសើរអើយ វីក្មេងទាំងពីរ គឺចៅជាលីនិងមេក្រស្នា ជាចៅតំណរាជ្យព្រះអង្គនោះ អញខ្ញុំឱ្យទៅជាទានព្រាហ្មណ៍ហើយ ក្រែងព្រះអង្គបានឃើញយល់ផង សូមទានព្រះអង្គសម្តែងថ្លែងប្រាប់យើងខ្ញុំ ឱ្យឆាប់កុំបីយូរឡើយ ថាបើព្រះអង្គមិនសម្តែងថ្លែងប្រាប់ហើយ សមយើងខ្ញុំទាំងពីរនឹងក្ស័យប្រល័យជីវិតប្រាកដហោង ។

រាជា អាហ ក្សិណនោះ ព្រះបាទស្រីសញ្ជ័យ ព្រះអង្គជ្រាបហើយមានព្រះបន្ទូលថា ៖

ឯតេ កុមារា និក្ខិតា ជាលី កណ្ហាជិនា ចុភោ
ព្រាហ្មណស្ស ជនំ ឧត្វា បុត្ត មា ភាយិ អស្សសីតិ ។

ម្នាលបាអើយ វីកុមារទាំងពីរគឺចៅជាលីនិងមេក្រស្នា អញលោះរួចចេញអំពីព្រាហ្មណ៍ហើយ កុំបាចប់បារម្ភឡើយ ចូរបាដកដង្ហើមចេញចូលឱ្យធូរស្រួលសុខសប្បាយទៅហោង ។

តំ សុត្វា មហាសត្តោ បដិលទ្ធស្សាសោ បិតរា សទ្ធឹ បដិសណ្ឋារមកាសិ កាលនោះព្រះមហាសត្វ ជ្រាបហើយមានព្រះ

Websites: WatKhemaraRatanaram.org or WatKhmers.org

រាជហឫទ័យនោះត្រេកអរសោទរ ធ្វើបដិសណ្ឋារៈប្រស្រ័យសាកសួរទទួលមួយអន្លើនឹងសម្តេចព្រះវររាជបិតាថា ៖

កច្ចិ នុ តាត កុសលំ　　　　កច្ចិ តាត អនាមយំ
កច្ចិ នុ តាត មេ មាតុ　　　　ចក្ខុ ន បរិហាយតីតិ ។

តាត បពិត្រសម្តេចព្រះវររាជបិតាធិរាជ ក្សត្រថ្លាប្រសើរអើយ រីព្រះអង្គគង់នៅនគរឯនាយនោះ តើញុាំងមានជម្ងឺអាពាធព្យាធិរោគាជរាមកបៀតបៀនព្រះអង្គឬទេ ។ រីទុក្ខភ័យចង្រៃឧបទ្រពផងទាំងឡាយ ញុាំងកើតមានឬទេ ។ មួយសោត រីព្រះនេត្រសម្តេចព្រះវរមាតាខ្ញុំ តើងងឹតហើយឬនៅឡើយទេ ? ។

រាជា អាហ ទើបសម្តេចព្រះមហាក្សត្រមានព្រះបន្ទូលថា ៖

កុសលញ្ចេវ មេ បុត្ត　　　　អថោ បុត្ត អនាមយំ
អថោ ច បុត្ត តេ មាតុ　　　　ចក្ខុ ន បរិហាយតីតិ ។

ម្នាលកូនអើយ រីជម្ងឺអាពាធព្យាធិរោគា នឹងមានមកបៀតបៀនយើងនោះ ឥតអង្គឹមានឡើយ រីទុក្ខសោករោគភ័យចង្រៃផងទាំងឡាយ នឹងមានមកដល់ខ្លួនយើងនោះ ឥតអង្គឹមានឡើយ រីព្រះ

Websites: WatKhemaraRatanaram.org or WatKhmers.org

នៃព្រះសម្តេចព្រះវរមាតាបានោះ ពុំទាន់ងងឹតនៅឡើយទេ ។

មហាសត្តោ អាហ ព្រះមហាសត្វឆ្លើយថា ៖

កច្ចិ អរោគំ យោគ្គន្តេ　　　កច្ចិ វហតិ វាហនំ
កច្ចិ ផីតោ ជនបទោ　　　កច្ចិ វុដ្ឋិ ន ឆិជ្ជតីតិ ។

បពិត្រសម្តេចព្រះវរបិតាអើយ រីគោក្របីដំរីសេះ យានជំនិះជំនាន់ អាចនាំព្រះអង្គទៅមកនោះគង់នៅឬទេ ។ ប្រការមួយសោត រីស្រុកក្រៅលំនៅជនបទផងទាំងឡាយ ញុំាងកើតមានភ្លៀងផ្គរប្រពៃសម្បូរនៃស្រូវអង្ករ មាសប្រាក់ឬទេ ។ ប្រការមួយសោត អស់មនុស្សម្នាមហាជនផងទាំងឡាយសុខសប្បាយជាទេឬ ។

រាជា អហ រីព្រះបាទស្រីសញ្ជ័យ ព្រះអង្គទ្រង់ព្រះសណ្តាប់ហើយ មានព្រះបន្ទូលថា ៖

អថោ អរោគំ យោគ្គម្មេ　　　អថោ វហតិ វាហនំ
អថោ ផីតោ ជនបទោ　　　អថោ វុដ្ឋិ ន ឆិជ្ជតីតិ ។

ហៃកូនស្ងួនសម្លាញ់ឪពុកអើយ រីគោក្របីដំរីសេះរទេះ នូវ

Websites: WatKhemaraRatanaram.org or WatKhmers.org

អស់យានជំនិះជំនាន់អញ អាចនាំទៅមកបាននោះ សឹងគង់នៅល្អ ។ រីស្រុកក្រៅលំនៅជនបទនោះផងសោត សឹងដ៏កើតភ្លៀងផ្គរប្រពៃ សម្បូរនូវស្រូវអង្ករ មាសប្រាក់នោះច្រើនពុំដែលដាច់ឡើយ ។

ឯវំ តេសំ តិណ្ណំ ខត្តិយានំ សល្លបន្តានញ្ចេវ ក្សិណនោះ ព្រះមហាក្សត្រទាំងបីព្រះអង្គ មានព្រះបន្ទូលសំណេះសំណាល នូវប្រការអម្បាលណោះហើយ ទើបព្រះនាងសុបារសុប្បតី ដ៏ជាសម្តេចព្រះវរមាតា ព្រះនាងលីលាចូលទៅមួយអន្លើ នូវអស់ស្រីព្រះស្នមក្រមការ សឹងដ៏មកចោមរោមជាបរិវារ ប្រយោជន៍ដើម្បីនឹងលីលាទៅកាន់សំណាក់ព្រះរាជបុត្រនោះហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលជាបាទព្រះគាថាដូច្នេះ ៖

ឥច្ចេវំ មន្តយន្តានំ មាតា នេសំ អជិស្សរ
រាជបុត្តី តិរិទ្វារេ បត្តិកា អនុចាហជា ។
តញ្ច ជិស្វាន អាយន្តី មាតរំ បុត្តគិទ្ធិនំ

វេស្សន្តរោ ច មទ្ទី ច បច្ចុគ្គន្ត្វា អវន្ទិសុំ ។
មទ្ទី ច សិរសា ចាទេ សស្សុយា អភិវាទយិ
មទ្ទី អហាញ្ហិ តេ អយ្យេ ចាទេ វន្ទាមិ តេ ហុសាតិ ។

ភិក្ខុអើយ រីព្រះនាងសុបារសុប្បតី ដ៏ជាសម្តេចព្រះវរមាតា ព្រះនាងលីលាចូលទៅដោយនូវព្រះបាទទទេ ឥតសុពណ៌បាទុក ទៅដល់ទ្វារព្រៃភ្នំគិរីវង្កតនាហៀបទៀបនឹងដល់ព្រះបរមសាលា ក៏ព្រះពោធិសត្វ នូវសម្តេចព្រះនាងមទ្រីទតទៅយល់ សម្តេចព្រះវរមាតាតាមមកដល់ប្រាកដ ហេតុតែសេចក្តីរឭកព្រះវរមាតានេះច្រើនណាស់មិញ ក៏ស្ទុះផ្លោះរត់ទៅទទួល ហើយក្រាបថ្វាយបង្គំ ។ ព្រះនាងមទ្រីក្រាបថ្វាយបង្គំប្រណម្យទូលថា បពិត្រព្រះមេអម្ចាស់អើយ ខ្ញុំអម្ចាស់នេះឯង ឈ្មោះនាងមទ្រីជាកូនប្រសាព្រះអង្គ មកក្រាបថ្វាយបង្គំប្រណម្យនៅក្រោមល្អងធូលីព្រះបាទ ។

រីក្សត្រទាំងបួនព្រះអង្គ បន្ទោបង់នូវទុក្ខសោក គង់បានបន្តិចទៅកូវ ។ ចៅជាលីនិងនាងក្រស្នា ក៏លីលាមកមួយអន្លើ នឹងអស់ក្មេងប្រុសស្រី ដ៏ចោមរោមជាបរិវារ ។ ក្សិណនោះព្រះនាងមទ្រីទតទៅ

Websites: WatKhemaraRatanaram.org or WatKhmers.org

យល់ព្រះរាជបុត្រទាំងពីរនោះហើយ ក៏ពុំអាចដើម្បីនឹងទប់ទល់តម្កល់អាត្មាភាពបានឡើយ សឹងស្ទុះផ្លោះទៅទទួលកូន បីដូចសត្វម្រឹគភ្លឹករលឹកកូន មានប្រការនោះម្ដេចមិញ រីព្រះនាងមទ្រីស្ទុះទៅទទួលកូននោះ មានឧបមេយ្យដូច្នោះហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថៃងប្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសាន្ទូវបាទព្រះគាថាដូច្នេះ ៖

មទ្ទិញ្ច បុត្តកា ទិស្វា ទូរតោ សោត្ថិមាគតា
កន្ទន្តា អភិធាវឹសុ វច្ឆា ពាលាវ មាតរំ ។
មទ្ទី ច បុត្តកេ ទិស្វា ទូរតោ សោត្ថិមាគតេ
វារុណិវ បវេធេន្តី ថនធារាភិសិញ្ចថាតិ ។

ហៃភិក្ខុអើយ កាលនោះព្រះរាជបុត្រទាំងពីរ បានមកពីចម្ងាយដោយសេរីសួស្ដី គ្រាន់តែក្រឡេកឃើញសម្ដេចព្រះមទ្រីជាព្រះវរមាតា ក៏ស្ទុះផ្លោះទៅទទួលព្រះមាតា ទ្រង់ព្រះកន្សែងថ្លែងពិលាបបីដូចកូនគោស្ទុះផ្លោះទៅទទួលមេវាដូច្នោះ ។ ឯសម្ដេចព្រះនាងមទ្រី

Websites: WatKhemaraRatanaram.org or WatKhmers.org

គ្រាន់តែទតឃើញព្រះរាជបុត្រទាំងពីរមកពីចម្ងាយ ក៏មានរាងកាយញាប់ញ័ររន្ធត់ បីដូចមេមត់ខ្មោចជាន់ ព្រះនាងទ្រង់ព្រះកន្សែងពិលាបពន់ពេកក្រៃ មួយអន្លើនឹងព្រះរាជបុត្រាបុត្រី ដ៏មានព្រះសរីរៈញាប់ញ័រចំប្រប់ ទ្រង់ដួលសន្លប់ទាំងជំហរនៅលើក្រឡាមហាប្រឹថពី ។ រីព្រះរាជកុមារទាំងពីរ កាលណាបានយល់សម្តេចព្រះវរមាតា ដួលសន្លប់ទៅដូច្នោះហើយ ក៏ទ្រង់ព្រះកន្សែងលុះដល់ដួលសន្លប់ទៅលើព្រះវរមាតានុ៎ះឯង ។ ខណៈនោះ រីទឹកព្រះក្សីរក៏ហូរចេញពីព្រះស្តនទាំងសងខាងហូរចូលទៅក្នុងព្រះឱស្ឋនៃព្រះរាជបុត្រាបុត្រី ថាបើគ្មានទឹកព្រះក្សីរហូរចូលព្រះឱស្ឋទេ សមព្រះរាជបុត្រទាំងពីរក្សិណក្ស័យប្រល័យជីវិតនោះទៀងប្រាកដហោង ។ រីព្រះបាទស្រីវេស្សន្តរទតទៅយល់ព្រះរាជបុត្រនិងព្រះរាជទេពី សឹងសន្លប់ដួលទៅដូច្នោះ ក៏ទ្រង់ស្ទុះទៅ ទ្រង់ព្រះកន្សែងថ្លែងពិលាប លុះដល់សន្លប់ដួលទៅ ដូចថៅជាលីនិងមេក្រស្នានោះឯង ។ រីសម្តេចព្រះវរមាតាបិតា កាលណាបើបានយល់សម្តេចព្រះរាជបុត្រទាំងពីរ នូវសម្តេចព្រះថៅទាំងពីរដួលសន្លប់ទៅដូច្នោះហើយ ស្តេចក៏ទ្រង់ព្រះកន្សែងថ្លែងពិលាប សឹងដ៏ដួលសន្លប់

Websites: WatKhemaraRatanaram.org or WatKhmers.org

ទៅនៅឰដ៏ឋាននោះឯង ។ រីអាមាត្យទាំង ៦ ម៉ឺន មួយអន្លើនូវអស់ពលទាំងឡាយ កាលណាបើបានយល់ព្រះមហាក្សត្រទាំង ៦ អង្គ សឹងដ៏សន្លប់ទៅហើយ ក៏មិនអាចទប់ទល់តម្កល់អាត្មាភាពបានឡើយ សឹងដ៏ទ្រហោយំដំទ្រូង សន្លប់ទៅអស់ទាំងប្រឡុងព្រះបរមសាលា មានឧបមាបីដូចខ្យល់យុគន្តវាត បោកបក់ព្រៃសាលវ័ន ឱ្យដួលក្រាបរាបទៅ មានប្រការនោះដូចម្តេចមិញ ។ រីទំនួញសព្ទឃោបំ នាំឱ្យអស់អាមាត្យទាំង ៦ ម៉ឺននោះ ដួលសន្លប់ទៅ ក៏មានឧបមេយ្យដូច្នោះហោង ។

រីក្រឡាមហាប្រឹថពីសោត សឹងដ៏កក្រើករំពើកទាំងភ្នំគិរីវង្កតបពិត ។ រីមហាសមុទ្រទាំងបួនសោត សឹងដ៏ពុះពោរជោរជន់រំជំរំជែងរលកបោកបែកជាផ្កាត្រែង ច្រឡើសលើសក្រៃលែងនឹងមាត់ច្រាំង ។ រីភ្នំព្រះសុមេរុរាជបពិត ដ៏មានកំពូលឱនលំទោនទៅមក បីដូចចុងដំបងទងផ្តៅ គិតដ៏អ្នកបោះទៅក្នុងពពុរភ្លើង ឱ្យខ្លោចលំអោចសំបក ហើយយកមកបញ្ឈរ ដ៏ទន់ល្វន់ល្វាសទៅវិញទៅមក នោះមានប្រការដូចម្តេចមិញ រីភ្នំព្រះសុមេរុរាជ ក៏មានឧបមេយ្យដូច្នោះហោង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

បពិត្រអើយ វិសព្ទកោលាហលអំពល់រវល់ជាមួយនឹងក្រឡាមហាប្រឹថពី សឹងកើតមានរៀងរាបដរាបទៅដល់ឆកាមាវចរសួគ៌ទេវលោកនាយហោង ។

អថ សក្កោ ទេវរាជា ឆ ខត្តិយា សបរិសា វសេញ្ញិតោ ជាតា តេសុ ឯកោបិ ឧដ្ឋាយ កស្សចិ សរីរេ ឧទកំ សិញ្ចិតុំ សមត្ថោ នាម នត្ថិ ។ បពិត្រអើយ កាលនោះសម្តេចព្រះឥន្ទ្រាធិរាជ យល់ក្សត្រទាំង ៦ អង្គសន្លប់ទៅហើយ ទ្រង់ព្រះចិន្តាពិចារណាថា ភោ ក្សត្រទាំង ៦ អង្គនេះមិញ សឹងដ៏សន្លប់ហើយហ្ន៎ ! ថាបើអញយកទឹកកុណ្ឌីទៅស្រោចស្រង់ក្សត្រទាំង ៦ អង្គនោះ ក៏នឹងមានព្រះជន្មរស់ឡើងវិញហើយ សមអស់ពលទាំងនោះនឹងក្ស័យប្រល័យជីវិតប្រាកដ ។ ក៏បើដូច្នោះ អញនឹងបង្អុរនូវភ្លៀងបោក្ខរព័ស៌ឱ្យធ្លាក់ចុះមក ហើយអស់ពលផងទាំងនោះ ក៏នឹងមានជីវិតរស់ឡើងវិញ ។ ព្រះឥន្ទ្រទ្រង់ព្រះចិន្តានូវប្រការអម្បាលនោះហើយ ក្សិណនោះ មហាមេឃងងក៏ដាលឡើងជោរជន់ភ្លៀងបង្អុរធ្លាក់ចុះមក ថាបើអ្នកឯណាចង់ឱ្យទទឹកអើក៏ភ្លៀងនោះរមៀលជ្រុះចេញ បីដូចទឹករមៀលធ្លាក់ចេញពីស្លឹក

Websites: WatKhemaraRatanaram.org or WatKhmers.org

ឈូក ពុំអាចជិតជាប់នូវសរីរៈរាងកាយអ្នកនោះឡើយ ។

កាលនោះ ព្រះមហាក្សត្រទាំង ៦ ព្រះអង្គ កាលណាបើបានត្រូវភ្លៀងបោក្ខរព័សិជិតដូចដល់សរីរៈដូច្នោះហើយ ក៏មានដង្ហើមចេញចូលធូរជាសុខសប្បាយ ហើយព្រះពោធិសត្វឯងបានដោះឡើងផ្គុំជំនុំនឹងអស់ព្រះញាតិផង នូវអាមាត្យទាំង ៦ ម៉ឺន មួយអន្លើនឹងពលផងទាំងឡាយ ក៏មានជីវិតរស់ឡើងក្នុងកាលនោះហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាចថិធមិឯណា ពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសានូវបាទព្រះគាថាដូច្នេះ ៖

សមាគតាន ញាតីនំ មហាឃោសោ អជាយថ
បព្វតា សមនាទឹសុ មហី អាកម្បិតា អហុ ។
វុដ្ឋិធារំ បវត្តេន្តោ ទេវោ ថារស្សិ តាវទេ
អថ វេស្សន្តរោ រាជា ញាតីហិ សមគច្ឆថ ។
នត្តារោ សុណិសា បុត្តោ រាជា ទេវី ច ឯកតោ
យទា សមាគតា អាសុំ តទាសិ លោមហំសនំ ។

បញ្ជលិកា តស្ស យាចន្តិ　　រោទន្តា ភេរវេ រវេ
វេស្សន្តរញ្ច មទ្ទិញ្ច　　សព្វេ រដ្ឋា សមាគតា
ត្វំ នោសិ ឥស្សរោ រាជា　　រដ្ឋំ ការេថ នោ ឧភោ ។

ភិក្ខុអើយ កាលណាព្រះញាតិវង្សានុវង្សទាំងឡាយ ស្តេចមកជួបជុំព្រមព្រៀងគ្នាហើយ ក៏កើតមានសព្ទគឹកកងរំពងឡើង ជាយ៉ាងក្រៃលែង ភ្នំទាំងឡាយក៏បន្លឺសូរសព្ទញាប់ញ័រ ទាំងក្រឡាមហាប្រឹថពី ក៏កក្រើករំពើកពេកក្រៃ ។ មហាមេឃក៏បង្អុរភ្លៀងធ្លាក់ចុះមកគគុកគគាក់ ក្នុងមួយរំពេចន៑ុះឯង ។ កាលនោះ ព្រះបាទស្រីសញ្ជ័យនូវព្រះនាងសុបារសុប្បតីរាជទេវី ព្រះរាជឱរស ព្រះរាជសុណិសា និងព្រះរាជនត្តាទាំងពីរព្រះអង្គ សឹងដ៏មានដង្ហើមចេញចូល ធូរស្រួលហើយ ស្តេចដោះឡើងមកផ្គុំជំនុំគ្នាឰដ៏ឋានមួយ ។ លុះពួកព្រះញាតិមកសមាគមជុំគ្នាហើយ ក៏កើតមានហេតុជាអស្ចារ្យប្រាកដ គួរស្ញប់ស្ញែង បណ្តាអស់មុខមន្ត្រីសេនាបតី នូវអស់ពលផងទាំងឡាយ សឹងដ៏លើកកំបង់អញ្ជលីដាក់លើសិរសី ក្រាបថ្វាយបង្គំប្រណម្យអារាធនានិមន្តព្រះបាទស្រីវេស្សន្តរបវររាជឥសី នូវសម្តេចព្រះនាងមទ្រីថា

Websites: WatKhemaraRatanaram.org or WatKhmers.org

បពិត្រក្សត្រថ្លៃប្រសើរអើយ សូមព្រះអង្គស្តេចលីលាថ្កានព្រះនគរ ហើយស្តេចកាន់យកនូវស្វេតច្ឆ័ត្ររាជ្យសម្បត្តិ ឋិតនៅជាឥស្សរកំពូលនៃយើងខ្ញុំទាំងឡាយនេះហោង ។

**ឆត្តត្តិយបព្វំ និដ្ឋិតំ** បពិត្រអើយ អាត្មាភាពសម្តែងថ្លែងព្រះធម៌វិសេសទេសនា កណ្ឌឆក្សត្រនេះមិញ ដ៏ប្រដាប់ប្រដានីទៅនូវគាថា ៣៩ គាថា ក៏ចប់បរិបូណ៌ សមគួរដោយនូវវេលានេះឯងហោង ។៚

(ចប់កណ្ឌឆក្សត្រ ទី ១២ តែប៉ុណ្ណេះ)

Websites: WatKhemaraRatanaram.org or WatKhmers.org

វាយខំព្យូទ័រសាឡើងវិញ

ដោយ

**ភិក្ខុ ភិក្ខុកិរតោ ឡាយ រិន**

និង

ត្រួតពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ

ដោយ

**លោកគ្រូ ធម្មនាថ ផនប្រសិទ្ធី**

ដើម្បីផ្សព្វផ្សាយ ជូនជាធម្មទាន តាមវិបសាយ

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទានឈ្នះអស់ទានទាំងពួង

ញ៉ុក . ថែម

# មហាវេស្សន្តរជាតក



កណ្ឌទី ១២

ផ្សាយឡើងវិញ "[illegible]"
រក្សាសិទ្ធិគ្រប់យ៉ាង
ព.ស ២៥៤៩ គ.ស ២០០៦